STATE SCHOOLS' RELIEF

State Schools' Relief (SSR) (អង្គការសម្រាលបន្ទុករបស់សាលារៀនរដ្ឋ) មានមោទនភាពក្នុងការប្រកាសថា រដ្ឋាភិបាលរដ្ឋវិចថូរៀបានធ្វើជាដៃគូជាមួយនឹង SSR ជាថ្មីម្តងទៀតដើម្បីផ្តត់ផ្គង់កម្មវិធី Glasses for Kids (GFK) (វ៉ែនតាសម្រាប់កុមារ) នៅចន្លោះឆ្នាំ 2024 និង 2027។ កម្មវិធី GFK មានបំណងលុបបំបាត់ការខូចភ្នែកដែលអាចជាឧបសគ្គដល់ការចូលរួមក្នុងការសិក្សាដោយធ្វើការធានាថា សិស្សដែលមានសិទ្ធទទួល ត្រូវបានគាំទ្រពេញទំហឹងក្នុងការចូលរួមក្នុងការអប់រំចាប់តាំងពីឆ្នាំដំបូង។ កម្មវិធី GFK មានបំណងទៅពិនិត្យសាលាបឋមសិក្សា និងសាលាឯកទេសចំនួន 770 ហើយកំណត់គោលដៅរហូតដល់ទៅ 108,000 សិស្សពីថ្នាក់ត្រៀម (Prep) – ថ្នាក់ទី 3 សម្រាប់ការពិនិត្យចក្ខុវិស័យ (vision screening) លើកដំបូងក្នុងអំឡុងកម្មវិធីនេះ។ ប្រសិនបើត្រូវការ ការធ្វើតេស្តភ្នែកគ្រប់ជ្រុងជ្រោយ ហើយវ៉ែនតានឹងត្រូវបានផ្តល់ឲ្យសិស្សដែលចូលរួមដោយឥតគិតថ្លៃ។

**ស្កេនកូដ QR (QR code) ហើយមើលវីដេអូអំពីវ៉ែនតាសម្រាប់កុមារនៅទីនេះ**




## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកយើងខ្ញុំថ្ងៃនេះ!

**Lisa MacKinven**
នាយកកម្មវិធី Glasses for Kids
អ៊ីមែល៖**glassesforkids@ssr.net.au**

**State Schools' Relief**
PO BOX 4525
Dandenong South VIC 3164

STATE SCHOOLS' RELIEF

VICTORIA State Government | Department of Education

# GLASSES FOR KIDS

## ព័ត៌មានសម្រាប់គ្រួសារ



### តើកម្មវិធី Glasses for Kids ដំណើរការដោយរបៀបណា?

- កម្មវិធី GFK ធ្វើជាដៃគូជាមួយអ្នកឯកទេសពិនិត្យភ្នែកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលនឹងទៅសាលារបស់អ្នក ហើយផ្តល់ឲ្យកូនអ្នកធ្វើការពិនិត្យចក្ខុវិស័យដំបូង និងបើត្រូវការ ការធ្វើតេស្តថែមទៀតហើយនិងវ៉ែនតា ដោយឥតគិតថ្លៃ។
- គ្រប់ការពិនិត្យចក្ខុវិស័យ និងការធ្វើតេស្តទាំងអស់ នឹងធ្វើឡើងក្នុងម៉ោងសាលា។

### តើកូនខ្ញុំអាចចូលរួមក្នុងកម្មវិធីនេះដោយរបៀបណា?

- សូមបញ្ជូនទម្រង់បែបបទយល់ព្រម និងកម្រងសំណួររបស់អ្នកឯកទេសពិនិត្យភ្នែក ទៅសាលាវិញឲ្យបានទាន់ថ្ងៃកំណត់។

### តើខ្ញុំបានលទ្ធផលរបស់កូនខ្ញុំដោយវិធីណា?

- កូនរបស់អ្នកនឹងទទួលបានលិខិតមួយច្បាប់អំពីលទ្ធផលនៃការពិនិត្យចក្ខុវិស័យរបស់ពួកគេ ដើម្បីយកមកផ្ទះ។

### ចុះបើកូនរបស់ខ្ញុំត្រូវការវ៉ែនតា?

- ប្រសិនបើអ្នកឯកទេសពិនិត្យភ្នែកចេញវេជ្ជបញ្ជាវ៉ែនតាឲ្យកូនរបស់អ្នក កម្មវិធី GFK នឹងផ្តល់វ៉ែនតានោះជូនអ្នកដោយឥតគិតថ្លៃ។
- កូនរបស់អ្នកនឹងមានឱកាសជ្រើសរើសវ៉ែនតារបស់ខ្លួន ហើយនិងបំពាក់នៅថ្ងៃនោះ។
- កូនរបស់អ្នកនឹងត្រូវបានផ្តល់លិខិតមួយច្បាប់ ដែលរៀបរាប់ថាហេតុអ្វីបានជាគេចេញវេជ្ជបញ្ជាវ៉ែនតា។

### តើអ្នកណាខ្លះអាចចូលរួម?

- សាលាបឋមសិក្សា៖ សិស្សថ្នាក់ត្រៀម – ថ្នាក់ទី 3
- សាលាឯកទេស៖ សិស្សអាយុពី 5 ទៅ 10 ឆ្នាំ

### តើកុមារដែលបច្ចុប្បន្ននេះមានពាក់វ៉ែនតា អាចចូលរួមក្នុង GFK បានទេ ?

- បាទ/ចាស ពួកគេអាច ប្រសិនបើវ៉ែនតារបស់ពួកគេមានចំណាស់ក្រោម 12 ខែ សូមផ្តល់វេជ្ជបញ្ជាវ៉ែនតាចុងក្រោយ ប្រសិនបើមាន។
- ប្រសិនបើកូនរបស់អ្នកមានការថែទាំដោយអ្នកឯកទេសពិនិត្យភ្នែកផ្សេងទៀត សូមចែករំលែកព័ត៌មានដែលពាក់ព័ន្ធ ក្នុងកម្រងសំណួររបស់អ្នកឯកទេសពិនិត្យភ្នែក។

### តើខ្ញុំត្រូវតែបញ្ជូនទម្រង់ឯកសារដាច់ដោយឡែកពីគ្នាសម្រាប់កូនម្នាក់ៗឬ?

- បាទ/ចាស សិស្សម្នាក់ៗត្រូវតែមានទម្រង់បែបបទយល់ព្រមដែលបានចុះហត្ថលេខា និងកម្រងសំណួររបស់អ្នកឯកទេសពិនិត្យភ្នែក។

### តើខ្ញុំត្រូវតែផ្តល់ព័ត៌មានមេឌីឃែរដែរទេ?

- បាទ/ចាស ការធ្វើតេស្តណាមួយដែលត្រូវការធ្វើនៅថ្ងៃនៃការទៅជួបអាចត្រូវបានគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋតាមរយៈមេឌីឃែរ។
- ទោះជាយ៉ាងណាក្តី ប្រសិនបើកូនរបស់អ្នកមិនមានប័ណ្ណមេឌីឃែរទេ គាត់នៅតែអាចចូលរួមក្នុងកម្មវិធីនេះបាន។

### តើមានអ្វីកើតឡើងប្រសិនបើវ៉ែនតានោះខូច?

- កម្មវិធី GFK នឹងផ្តល់វ៉ែនតាថ្មីមួយ(1) ជំនួសឲ្យតែវ៉ែនតាលើកដំបូងនោះ
មានចំណាស់តិចជាង 12 ខែ។
- ប្រសិនបើបន្ទាប់មក វ៉ែនតាដែលជួសនោះខូចឬបាត់ គ្រួសារ និង/ឬសាលាអាចទិញមួយ ឬច្រើនថែមទៀត ពី SSR ។

# ជំហានសាមញ្ញៗ 4 ដើម្បីចូលរួមក្នុងកម្មវិធី Glasses for Kids ...

1. ចូរអានខិតប័ណ្ណព័ត៌មានសម្រាប់គ្រួសារ
2. ចូរបំពេញទម្រង់បែបបទយល់ព្រម និងកម្រងសំណួររបស់អ្នកឯកទេសពិនិត្យភ្នែក
3. ចូរផ្តល់ទម្រង់បែបបទទាំងពីរទៅសាលាវិញ
4. សូមឲ្យប្រាកដថា កូនរបស់អ្នកស្ថិតនៅសាលារៀននៅថ្ងៃពិនិត្យ

